ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបំពេញបន្ថែមក្រុមប្រឹក្សាកំណែទម្រង់

## កងយោធពលខេមរភូមិន្ទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រម លេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ .
- បានឃើញព្រះរាជក្រម លេខនស/រកត/០៣៩៩/៧២ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ .
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ .
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី ១១ ខែមីនា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអង្គភាពសំរាប់សំរបសំរួលបញ្ចូលកងទ័ពរំសាយ និងសមាហរណកម្ម ចូលក្នុងសង្គមជាតិ អតីតទាហានខ្មែរក្រហម .
- បានឃើញអនុក្រឹត្យ លេខ៤៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែឧសភា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។

## សំរេច

**មាត្រា១:** ត្រូវបានបំពេញបន្ថែម សមាសភាពក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ និងកែសំរួលសមាសភាពអគ្គលេខាធិការដ្ឋាន ដូចខាងក្រោម :

ក - បំពេញបន្ថែម :

១ - ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ ជា **អនុប្រធានអចិន្ត្រៃយ៍** ។

ខ - កែសំរួល និងបន្ថែមសមាសភាពអគ្គលេខាធិការដ្ឋាន ទទួលបន្ទុកការងារអចិន្ត្រៃយ៍ ដូចខាងក្រោម ៖

១ - កែសំរួល ឧត្តមសេនីយ៍ទោ **មាស សំអុល** នាយក នាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ ជា **អគ្គលេខាធិការរង** ជំនួសឧត្តមសេនីយ៍ទោ **ពុត សំអោក** ។

២ - បំពេញបន្ថែម វរសេនីយ៍ឯក **ឈុន សារឿន** នាយករង នាយកដ្ឋានបុគ្គលិក ជា **សមាជិកអចិន្ត្រៃយ៍**

៣ -បំពេញបន្ថែម វរសេនីយ៍ឯក **ឈុម រតនា** នាយករង ទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន ជា **សមាជិកអចិន្ត្រៃយ៍** ។

**មាត្រា២** : សមាជិកទាំងអស់ដែលបានបំពេញបន្ថែម និងបានកែសំរួល ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់សហប្រធានក្រុមប្រឹក្សាកំណែទម្រង់កងយោធពលខេមរភូមិន្ទ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ១៨ ខែ ០៣ ឆ្នាំ២០០២

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com